# ច្បាប់ ប្រកាសនីយបត្រតក្កកម្ម នៅកម្ពុជា

Abacus IP
Cambodia

កក្កដា ២០១៥

info@abacus-ip.com
+៨៥៥ (0) ១២ ២១៥ ១២៩
www.abacus-ip.com

៨៣៦ ផ្លូវលំ ចំការឪឡឹក
សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

info@abacus-ip.com
+855 (0)12 215 129
436 Plov Lum, Chamkar Orvleuk
Sangkat Kakab, Khan Posenchey
Phnom Penh, Cambodia

## សេចក្តីផ្តើម

ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៣ ដែលជាផ្នែកមួយរបស់ប្រទេសកម្ពុជា ក្នុងការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដែលបានផ្តល់សិទ្ធិផ្តាច់មុខជូនដល់តក្កករក្នុងការបញ្ចេញអោយដឹងដល់សាធារណៈជននូវតក្កកម្មថ្មី។ ប្រកាសនីយបត្រតក្កកម្ម ចុះបញ្ជីដោយនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងខណៈពេលដែលសំណុំលិខិតដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម បានដាក់អស់ជាងមួយទសវត្សរ៍ ប្រកាសនីយបត្រតក្កកម្មដំបូងក៏ត្រូវបានចុះបញ្ជី តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គភាពកម្មសិទ្ធិបញ្ញានៃប្រទេសសឹង្ហបុរី។ បើទោះបីជា ប្រទេសកម្ពុជាមិនមែនជាសមាជិកនៃសន្ធិសញ្ញានៃកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (Patent Cooperation Treaty) ក៏ដោយ ក៏ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មអនុញ្ញាតអោយមានការទទួលចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបរទេសនៅក្នុងប្រទេសកម្ពុជា និងទទួលស្គាល់កាលបរិច្ឆេទអាទិភាពផងដែរ។ ច្បាប់នេះត្រូវបានបំពេញបន្ថែមដោយប្រកាសស្តីពី នីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦។

## តក្កកម្មដែលអាចផ្តល់ប្រកាសនីយបត្រតក្កកម្មបាន

តក្កកម្មក្នុងន័យច្បាប់ គឺជា "គំនិតរបស់តក្កករដែលអាចយកទៅអនុវត្តបាននៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា" ដែលអាចជាផលិតផល ឬដំណើរការផលិតកម្ម ឬអាចទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។[1] តក្កកម្មណាមួយក៏អាចជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មដែរ លើកលែងតែតក្កកម្មដូចខាងក្រោម:[2]

- ការរកឃើញទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា
- គម្រោងការ ក្បួន ឬវិធីសាស្ត្រសម្រាប់ធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញា

[1] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា៣

[2] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា៤

© 2015 Abacus IP 

សុទ្ធសាធ ឬ សម្រាប់លេងល្បែងកំសាន្ត

- វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្សឬសត្វ ដោយការវះកាត់ ឬដោយការព្យាបាល ក៏ដូច ជាវិធីសាស្ត្រវិនិច្ឆ័យរោគ ដែលបានអនុវត្តលើរាងកាយមនុស្ស ឬសត្វ។ បទប្បញ្ញត្តិនេះមិនយក មកអនុវត្តចំពោះផលិតផលទាំងឡាយដែលយកមកប្រើក្នុងវិធីសាស្ត្រខាងលើនេះទេ
- ផលិតផលឱសថ
- រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរការកកើត តាមលក្ខណៈជីវសាស្ត្រ សំខាន់ៗសម្រាប់ផលិតកម្មរុក្ខជាតិ ឬសត្វ
- ប្រភេទផ្សេងៗនៃពូជរុក្ខជាតិណាមួយ។[3]

កុំព្យូទ័រសូហ្វវែរក៏ត្រូវអាចផ្តល់ប្រកាសនីយបត្រតក្កកម្មបានដែរ ប្រសិនបើ:[4]

- តក្កកម្មជាដំណើរការផលិតកម្ម ដែលជាផ្នែកទាំងមូល ឬផ្នែកខ្លះ មានជំហានជាច្រើនដែលត្រូវ អនុវត្តដោយកុំព្យូទ័រ និងត្រូវបញ្ជាដោយកម្មវិធីកុំព្យូទ័រ និង
- តក្កកម្មជាផលិតផល ដែលមានធាតុនៃតក្កកម្ម ដែលអនុវត្តដោយកុំព្យូទ័ររួមមានជាពិសេស:
    - កូដកម្មវិធីកុំព្យូទ័រដែលម៉ាស៊ីនអាចអានបាន ដែលអាចស្តុកទុកនៅក្នុងឧបករណ៍មាន រូបរាងជាក់ស្តែង ដូចជាហ្លូភីឌីស កុំព្យូទ័រហាដដ្រាយ្វ ឬកុំព្យូទ័រម៉េម៉ូរី និង
    - កុំព្យូទ័រសម្រាប់គោលបំណងទូទៅ ដែលភាពថ្មីរបស់វាលើស្នាដៃមុនលេចចេញជា បឋមដោយការផ្គុំបញ្ចូលវាជាមួយកម្មវិធីកុំព្យូទ័រជាក់លាក់មួយ។

## ភាពថ្មី

តម្រូវការដំបូងសំរាប់តក្កកម្ម ដែលអាចទទួលប្រកាសនីយបត្រតក្កកម្មបាន គឺតក្កកម្មថ្មី មានន័យថា តក្កកម្មនោះពុំទាន់មានអ្នកណាបានរកឃើញពីមុន។[5]

ការរកឃើញពីមុន គឺតក្កកម្មដែលសាធារណជននៅកន្លែងណាមួយនៅលើពិភពលោកបានដឹង មុន កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ តាមរយៈការ ផ្សព្វផ្សាយ ដោយប្រើរូបភាពជាក់ស្តែង ឬដោយផ្ទាល់មាត់ តាមរយៈការប្រើប្រាស់តក្កកម្មនោះ ឬតាមរយៈ មធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត។ មិនត្រូវចាត់ទុកថាជាការដឹងដល់សាធារណជនក្នុងករណីដូចខាងក្រោម:[6]

---

[3] ពូជរុក្ខជាតិត្រូវបានការពារក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ (ព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៥)

[4] ប្រកាស មាត្រា៨៤

[5] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៦

[6] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៦

© 2015 Abacus IP 

- ការដឹងដល់សាធារណជននូវតក្កកម្ម ដែលបានកើតឡើងក្នុងអំឡុងពេលដប់ពីរ (១២) ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ។
- ការធ្វើអោយលេចឮខ្ចរខ្ចាយព័ត៌មានស្តីអំពីតក្កកម្ម តាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់ភាគីទីបីទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជន ដែលបណ្តាលអោយលេចឮខ្ចរខ្ចាយព័ត៌មាននេះ។

## ជំហានរកឃើញថ្មី

ទីពីរ តក្កកម្មត្រូវមាន "ជំហានរកឃើញថ្មី"។[7] តក្កកម្មត្រូវចាត់ទុកថាមានជំហានរកឃើញថ្មី ប្រសិនបើតក្កកម្មនោះ មិនអាចអោយបុគ្គលណាដែលមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន។

## ភាពអនុវត្តបានក្នុងវិស័យឧស្សាហកម្ម

ទីបី តក្កកម្មត្រូវតែអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម មានន័យថា តក្កកម្មនោះអាចត្រូវផលិត ឬត្រូវប្រើប្រាស់ នៅក្នុងប្រភេទណាមួយនៃឧស្សាហកម្មបាន។[8] ក៏ប៉ុន្តែ ប្រសិនការធ្វើអាជីវកម្មពាណិជ្ជកម្មតក្កកម្មនោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ ប៉ះពាល់ដល់ជីវិតមនុស្ស សត្វ រុក្ខជាតិ ឬសុខភាព ធ្វើអោយខូចបរិស្ថានធ្ងន់ធ្ងរ ឬត្រូវបានច្បាប់ហាមឃាត់មិនត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្មឡើយ។[9]

## សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម និងការដាក់ឈ្មោះតក្កករ

សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ជាកម្មសិទ្ធិរបស់តក្កករម្នាក់ ឬច្រើននាក់។[10] នៅពេលដែលមានបុគ្គលពីរនាក់ ឬច្រើននាក់ បានរកឃើញដោយឡែកៗពីគ្នានូវតក្កកម្មមួយដូចគ្នា បុគ្គលណាដែលបានដាក់សំណុំលិខិតស្នើសុំដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ឬមានកាលបរិច្ឆេទអាទិភាពមុនគេបង្អស់ ហើយបានប្រកាសសុពលភាពនៃកាលបរិច្ឆេទអាទិភាពនោះ ត្រូវទទួលសិទ្ធិជាម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ។[11] ចំពោះការងារដែលស្ថិតនៅក្រោមកិច្ចសន្យាការងារ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ត្រូវតែជា

---

[7] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៧

[8] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៨

[9] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៩

[10] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១០ និង ១១

[11] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១២

កម្មសិទ្ធិរបស់និយោជក លើកលែងតែមានការព្រមព្រៀងដោយឡែក។[12] ឈ្មោះរបស់តក្កករត្រូវតែកត់ត្រាក្នុងប្រកាសនីយបត្រតក្កកម្មនោះ លើកលែងតែតក្កករចង់ដាក់ជាអនាមិក។[13]

## សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម

សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម អាចដាក់នៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ សំណុំលិខិតនោះត្រូវមាន សេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាងមួយ ឬច្រើន គំនូសបង្ហាញក្នុងករណីចាំបាច់ដើម្បីអោយយល់អំពីតក្កកម្មនោះ ខ្លឹមសារសង្ខេប នឹងកម្រៃសេវាសាធារណៈ។[14] សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់ និងពេញលេញ ដើម្បីអោយបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។[15] សំណុំលិខិតស្នើសុំអាចដកវិញបាន អាចបំបែក ឬក៏អាចកែតម្រូវ រហូតដល់សំណុំលិខិតស្នើសុំនោះត្រឹមត្រូវ នឹងអាចផ្តល់ប្រកាសនីយបត្រតក្កកម្មបាន។[16]

សំណុំលិខិតស្នើសុំអាចប្រកាសអំពីអាទិភាព ដោយផ្អែកលើសំណុំលិខិតស្នើសុំនៅក្នុងប្រទេសមួយ ឬនៅក្នុងតំបន់មួយ ឬនៅអន្តរជាតិ ដោយយោងតាមអនុសញ្ញាទីក្រុងប៉ារីស។ ក្នុងករណីនេះ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនិងស្នើសុំឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ ដោយបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ក៏ដូចជារបាយការណ៍ស្រាវជ្រាវ ឬលទ្ធផលនៃការពិនិត្យ ឬសកម្មភាពរបស់ការិយាល័យបរទេសនោះ។

សេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលទាក់ទងនិងការផ្តល់ប្រកាសនីយបត្រតក្កកម្មអាចធ្វើការប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ក្នុងរយៈពេលបី (៣)ខែ ចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

ចាប់តាំងពីខែមករា ឆ្នាំ២០១៥ អ្នកដាក់ពាក្យសុំអាចដាក់ពាក្យស្នើសុំប្រកាសនីបត្រតក្កកម្មបាន តាមរយៈអង្គភាពកម្មសិទ្ធិបញ្ញានៃប្រទេសសឹង្ហបុរី (IPOS)។ អង្គភាពកម្មសិទ្ធិបញ្ញានៃប្រទេសសឹង្ហបុរី និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃប្រទេសកម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នា អនុញ្ញាតអោយមានការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសកម្ពុជា តាមរយៈអាជ្ញាធរសឹង្ហបុរី ឬក៏ដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសសឹង្ហបុរី តាមរយៈអាជ្ញាធរកម្ពុជា។ អនុស្សរណៈនៃការយោគយល់គ្នាមានសុពលភាពសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ ចាប់ពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ និងអាចត្រូវបន្តរជាថ្មីបានដោយមានការព្រមព្រៀងគ្នាពីភាគីទាំងពីរ។

---

[12] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១៤

[13] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១៥

[14] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១៦

[15] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១៨

[16] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ២២ និង ២៤

## រយៈពេលនៃការការពារ និងការបង់កម្រៃប្រចាំឆ្នាំ

ប្រកាសនីយបត្រតក្កកម្មមានសុពលភាពរយៈពេលម្ភៃ (២០) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី និងត្រូវបង់កម្រៃប្រចាំឆ្នាំ ដើម្បីរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្មដូចមានខាងក្រោមៈ[17]

| ឆ្នាំ | កម្រៃសេវា (ដុល្លាអាមេរិក) | ឆ្នាំ | កម្រៃសេវា (ដុល្លាអាមេរិក) |
|---|---|---|---|
| ឆ្នាំទី ១ | - | ឆ្នាំទី ១១ | ៣៥០ |
| ឆ្នាំទី ២ | ២០ | ឆ្នាំទី ១២ | ៤០០ |
| ឆ្នាំទី ៣ | ២០ | ឆ្នាំទី ១៣ | ៤៥០ |
| ឆ្នាំទី ៤ | ៤០ | ឆ្នាំទី ១៤ | ៥០០ |
| ឆ្នាំទី ៥ | ១០០ | ឆ្នាំទី ១៥ | ៥៥០ |
| ឆ្នាំទី ៦ | ១៤០ | ឆ្នាំទី ១៦ | ៦១០ |
| ឆ្នាំទី ៧ | ១៨០ | ឆ្នាំទី ១៧ | ៦៧០ |
| ឆ្នាំទី ៨ | ២២០ | ឆ្នាំទី ១៨ | ៧៤០ |
| ឆ្នាំទី ៩ | ២៦០ | ឆ្នាំទី ១៩ | ៨១០ |
| ឆ្នាំទី ១០ | ៣០០ | ឆ្នាំទី ២០ | ៨៩០ |

## ការរួមបញ្ចូលតែមួយនៃតក្កកម្ម ការកែតម្រូវ និង ការបំបែកសំណុំលិខិត

ប្រកាសនីយបត្រតក្កកម្ម ត្រូវតែពាក់ព័ន្ធទៅនឹងតក្កកម្មតែមួយគត់ ឬតក្កកម្មមួយក្រុមដែលទាក់ទងគ្នាបង្កើតបានជាទស្សនៈរួមមួយនៃតក្កកម្មនោះ។[18] សំណុំលិខិតស្នើសុំអាចធ្វើការកែតម្រូវបាន រហូតដល់ប្រកាសនីយបត្រតក្កកម្មនោះត្រូវបានផ្តល់ ប៉ុន្តែរាល់ការកែតម្រូវនោះមិនត្រូវអោយហួសពីខ្លឹមសារក្នុងសំណុំលិខិតស្នើសុំ

[17] ប្រកាសរួមស្តីពីកម្រៃសេវាសាធារណៈ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥

[18] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ២៣

ដំបូងឡើយ។[19] ស្រដៀងគ្នានេះ សំណុំលិខិតស្នើសុំក៏អាចធ្វើការបំបែកជាពីរ ឬច្រើនផងដែរ។[20]

## សិទ្ធិទទួលបានពីប្រកាសនីយបត្រគ្គកម្ម

សិទ្ធិចម្បងដែលទទួលបានមកពីប្រកាសនីយបត្រតក្កកម្ម គឺជាសិទ្ធិក្នុងការពារបុគ្គលដទៃទៀតមិនអោយធ្វើអាជីវកម្មលើតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មនោះ។[21] ការធ្វើអាជីវកម្មផលិតផលដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយរួមមាន ការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់ ការលក់ ការស្តុកទុកដើម្បីប្រើប្រាស់ ឬការប្រើប្រាស់។ សំរាប់ដំណើរការផលិតកម្ម ការធ្វើអាជីវកម្ម មានន័យថា ការប្រើប្រាស់ដំណើរការផលិតកម្មនោះ ឬការធ្វើអាជីវកម្មនូវផលិតផលដែលទទួលបានដោយផ្ទាល់ពីមធ្យោបាយនៃដំណើរការផលិតកម្មនោះ។[22]

ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាដែលរំលោភលើប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន ឬធ្វើសកម្មភាពទាំងឡាយណាដែលអាចនឹងបណ្តាលអោយកើតមានការរំលោភកើតឡើង។[23]

ការកំណត់សិទ្ធិដែលទទួលបានពីប្រកាសនីយបត្រតក្កកម្មមានដូចជា:[24]

- សកម្មភាពពាក់ព័ន្ធនឹងសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬដោយមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម
- សម្ភារៈនៅលើយានយន្តដែលចូលចតជាបណ្តោះអាសន្ន ក្នុងដែនដីនៃប្រទេសកម្ពុជា ឬចូលចតដោយឧបទ្ទវហេតុ
- ប្រើប្រាស់ក្នុងគោលបំណងពិសោធន៍
- ការប្រើប្រាស់តក្កកម្ម ឬក៏ធ្វើការរៀបចំអោយមានប្រសិទ្ធិភាព និងហ្មត់ចត់នូវតក្កកម្មនោះក្នុងការប្រើប្រាស់ មុនកាលបរិច្ឆេទអាទិភាព

  តាមបណ្តឹងរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬ អ្នកទទួលអាជ្ញាប័ណ្ណ ក្នុងកាលៈទេសៈជាក់ស្តែងណាមួយ តុលាការមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចដើម្បីទប់ស្កាត់ការរំលោភ ឬការរំលោភដែលប្រុងនឹងកើតមានឡើង សម្រេចអោយសងការខូចខាត និងផ្តល់នូវដំណោះស្រាយផ្សេងៗដែលមានចែងក្នុង

---

[19] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ២៤

[20] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ២៥

[21] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤១

[22] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤២

[23] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤៣

[24] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤៤

ច្បាប់ជាធរមាន។[25] លើសពីនេះទៅទៀត បុគ្គលណាមួយដែលរំលោភដោយចេតនា និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ទៅ ២០ លានរៀល (ប្រហែល ១.២៥០ – ៥.០០០ ដុល្លាអាមេរិក) ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ទៅ ៥ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ។[26] ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។[27]

## ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល និងអាជ្ញាប័ណ្ណបញ្ជា

សិទ្ធិទទួលបានពីប្រកាសនីយបត្រតក្កកម្មមិនពេញលេញនោះទេ សិទ្ធិនេះត្រូវមានការកម្រិតកំណត់សំរាប់ការធ្វើអាជីវកម្មដោយរាជរដ្ឋាភិបាល និងការចេញអាជ្ញាប័ណ្ណបញ្ជា។ រាជរដ្ឋាភិបាលកម្ពុជាអាចសម្រេចអោយអង្គភាពរដ្ឋ ឬតតិយជនធ្វើអាជីវកម្មលើតក្កកម្មបាន ទោះបីជាគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មក៏ដោយ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ជាពិសេសផ្នែកសន្តិសុខជាតិ អាហារូបត្ថម្ភ សុខាភិបាល ឬដើម្បីអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិសំខាន់ៗផ្សេងទៀត។[28] លើសពីនេះទៅទៀត ប្រសិនបើតុលាការមានសមត្ថកិច្ចវិនិច្ឆ័យថា ការប្រើប្រាស់ប្រកាសនីយបត្រតក្កកម្មរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬអ្នកទទួលអាជ្ញាប័ណ្ណមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង ប្រកាសនីយបត្រតក្កកម្មនោះនឹងអាចត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ឬ តតិយជនវិញ។[29] ក្នុងករណីណាក៏ដោយ ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិទទួលបាននូវសវនាការមួយ និងប្រាក់សំណងសមស្រប។[30]

បន្ថែមលើរាជរដ្ឋាភិបាល និងតតិយជន ច្បាប់ក៏អនុញ្ញាតអោយមានការផ្តល់អាជ្ញាប័ណ្ណបញ្ជាផងដែរ។ បុគ្គលណាមួយក៏អាចស្នើសុំទៅរដ្ឋមន្ត្រីសំរាប់អាជ្ញាប័ណ្ណបញ្ជា ក្នុងរយៈពេល៤ឆ្នាំ ក្រោយពីកាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ឬរយៈពេល៣ឆ្នាំ ក្រោយកាលបរិច្ឆេទផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយយកកាលបរិច្ឆេទណាមួយដែលផុតកំណត់ក្រោយគេ។ អាជ្ញាប័ណ្ណបញ្ជានឹងត្រូវផ្តល់ជូន ប្រសិនបើអាចបង្ហាញថាប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូនមិនត្រូវបានធ្វើអាជីវកម្ម ឬបានធ្វើអាជីវកម្មមិនពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[31] ក៏ប៉ុន្តែ ម្ចាស់ប្រកាសនីយបត្រតក្កកម្ម អាចទប់ស្កាត់ការផ្តល់អាជ្ញាប័ណ្ណបញ្ជាបានប្រសិនអាចស្រាយបំភ្លឺកាលៈទេសៈជាក់ស្តែងណាមួយ។[32] ម្ចាស់ប្រកាសនីយបត្រតក្កកម្ម នឹងត្រូវផ្តល់ជូននូវ

---

25 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១២៦

26 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១៣៣

27 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ១៣៣

28 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤៧

29 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤៧

30 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៤៧

31 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៥៦

32 ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៥៦

© 2015 Abacus IP

ប្រាក់សំណាងលើអាជ្ញាប័ណ្ណបញ្ហាជាមួយរាជរដ្ឋាភិបាល នឹងតតិយជន។[33]

## មោឃភាព

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំអោយទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្មបាន។[34] ការស្នើសុំមោឃភាពនឹងត្រូវបានផ្តល់ ប្រសិនបើអាចបង្ហាញថាប្រកាសនីយបត្រតក្កកម្មនោះមិនត្រឹមត្រូវ មិនមានភាពថ្មី មិនមានជំហានរកឃើញថ្មី មិនអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ឬក៏ការធ្វើអាជីវកម្មនោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬត្រូវបានហាមឃាត់ដោយច្បាប់។[35] លើសពីនេះទៀត ហេតុផលសំរាប់មោឃភាពប្រកាសនីយបត្រតក្កកម្មរួមបញ្ចូលទាំងភាពមិនពេញលេញនៃសេចក្តីអធិប្បាយ ភាពមិនត្រឹមត្រូវអំពីសេចក្តីអះអាង ឬភាពមិនគ្រប់គ្រាន់នូវគំនូសបង្ហាញ។[36]

[33] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៥៧

[34] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៦៥

[35] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៦៦

[36] ច្បាប់ប្រកាសនីយបត្រតក្កកម្ម មាត្រា ៦៦